អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងធ្វើរ៉ាកែតវាយសី**

**ចិត្តចលភាព៖** បំណិនចលនាតូច

៖ ការហ្វឹកហាត់បង្កើនកម្លាំងសម្របសម្រួលរវាងចលនាសាច់ដុំដៃ និងសាច់ដុំភ្នែក

**សិក្សាសង្គម៖** គំនូរនិងសកម្មភាពកសាង៖ ការយល់ដឹង និងពេញចិត្តចំពោះសិល្បៈតាមការបង្កើតរូបភាព

**បុរេគណិត៖** រង្វាស់រង្វាល់៖ បញ្ញបត្តិស្ដីពីរង្វាស់រង្វាល់៖ បញ្ញត្តិនៃរូបរាង និងលំហ

**គោលបំណង** ៖

**ចិត្តចលភាព៖** មានអំណត់ តស៊ូព្យាយាម និងសប្បាយរីករាយក្នុងការធ្វើអ្វីមួយ ឬលេងល្បែងឱ្យបានរឹងមាំ និងជោគជ័យ។

**បុរេគណិត** ៖ ប្រាប់បានពីរូបរាងសាមញ្ញពីធរណីមាត្រដូចជា៖ រូបរាងការេ ត្រីកោណ រង្វង់ និងចតុកោណកែងជាដើម…។

**សិក្សាសង្គម៖** ប្រាប់បានពីរបៀបនៃការបត់ រោយ ដេរ ត្បាញ សូនរូប គូរ ផាត់ពណ៌ ហែក កាត់ បិទ បត់… ដើម្បីបង្កើតជារូបភាពផ្សេងៗ។ ធ្វើឱ្យក្មេងៗមានសកម្មភាព រហ័សរហួន និងប្រុងប្រយ័ត្នក្នុងការចាប់កាន់ បត់ សូន គូរ ហែក និងផាត់ពណ៌ជាដើម…។

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ក្រដាសកេះ ស្កុតមុខពីរពណ៌ខ្មៅ ស្កុតថ្លា កន្ត្រៃ ក្រដាសរាមក្រាស់ ដីខ្មៅ និងដីខ្មៅពណ៌។

**កម្រិតសិក្សា** ៖ មធ្យម និង ខ្ពស់

**ការរៀបចំ** ៖ ត្រៀមសម្ភារទាំងអស់សម្រាប់លេងល្បែងនេះជាមួយកុមារ។

**សេចក្ដីណែនាំ៖**

1. ប្រាប់ពួកគេថាថ្ងៃនេះ ពួកគេនឹងទៅធ្វើរ៉ុកកែតវាយសីជាមួយអ្នក (គ្រូ)។
2. សួរពួកគេថា តើកូនៗធ្លាប់ស្គាល់កីឡាវាយសីអត់? ធ្លាប់លេងដែរឬទេ? លេងជាមួយអ្នកណា? នៅណា?

3. ចាប់ផ្ដើមធ្វើរ៉ុកកែតតែម្ដង៖
    - ប្រើកន្ត្រៃកាត់ក្រដាសកេះជារាងពងក្រពើ ឬរាងរង្វង់មូលក៏បានដែរ តាមការចូលចិត្តរបស់អ្នក ឬក្មេងៗ។
    - បន្ទាប់មកផាត់ពណ៌លើក្រដាសកេះដែលបាកាត់នោះ (គូរ និងផាត់ជារាងសំណាញ់ទាំងសងខាង) ហើយទុកវាមួយអន្លើសិន។
    - យកក្រដាសរាមក្រាស មកមូលវាជាដងរ៉ុកកែត ជារាងទីបដែលមានប្រវែលតាមការចង់បានរវស់អ្នក បន្ទាប់មកប្រើស្កុតថ្លារុំជុំវិញទីបនោះ ឱ្យបានរឹងមាំ
    - ប្រើកន្ត្រៃកាត់ ឬពុះវានៅផ្នែកខាងលើឱ្យចំកណ្ដាល
    - បន្ទាប់មកយកក្រដាសកេះដែលបានគូរ និងផាត់ពណ៌រួចនោះ មកគាបខាងលើដងរ៉ុកកែតនោះ ដោយប្រើស្កុតមុខពីរខ្មៅ បិទនៅចំចន្លោះទាំងសងខាងនៃដងរ៉ុកកែត (ប្រើល្មមនឹងឱ្យវាមានសភាពរឹងមាំជាការស្រេច)។
    - ធ្វើប៉ុណ្ណឹងជាការស្រេចតែម្ដង។
4. ប្រសិនបើអ្នកមានគ្រាប់វា អាចឱ្យក្មេងៗលេងវាបាន។ អ្នកអាចលេងល្បែងនេះនៅក្នុងសកម្មភាព ល្បែងប្រណាំងវាយប៉េងប៉ោងចូលក្នុងកន្ត្រក ដោយប្រើ រ៉ុកកែតនេះបាន។
5. ប៉ន្តែប្រសិនមិនទាន់មានទេ អ្នកអាចនិយាយថា ចាំលេងលេងល្បែងក្រោយបាន។
6. នៅពេលដែលកុមារធ្វើរួចរាល់ និងបានបញ្ចប់ ប្រាប់ឱ្យក្មេងៗជួយរៀបចំកន្លែងឱ្យបានស្អាតផងជាការស្រេច។